-យល់ឃើញថា ៖ ពាក្យបណ្តឹងនេះគ្មានឯកសារភស្តុតាងគ្រប់គ្រាន់ ដើម្បីបើកសវនាការតាមមាត្រា១១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺឲ្យក្រុមប្រឹក្សាធម្មនុញ្ញសំរេចបដិសេធពុំទទួលពាក្យបណ្តឹងតវ៉ានេះ ។

-យល់ឃើញថា ៖ សេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០៨-១៧១១/៩៨ គជប ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ១៩៩៨ មានមូលហេតុត្រឹមត្រូវហើយ ។

**សំរេច**

១-បដិសេធពាក្យបណ្តឹងជំទាស់ លេខ ១៦២/៩៨ នពក ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណបក្សហ្វ៊ុនស៊ិនប៉ិច ដែលទាក់ទងនឹងសេចក្តីសំរេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ០៨-១៧១១/៩៨ គជប ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ក្នុងការបដិសេធពាក្យបណ្តឹង លេខ ០៤៦-៩៨ នពក ចុះថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ១៩៩៨ ស្តីពីភាពមិនប្រក្រតីរបស់ស្រុកឧត្តុង្គ និងប្រធានភូមិ-ឃុំ ពីបទចិញ្ចាំសន្លឹកឆ្នោត ដោយជាអាសាបង់ ។

២-តម្កល់សេចក្តីសំរេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០៨-១៧១១/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ ទុកជាបានការពេញទាំងមូល ។

៣-សេចក្តីសំរេចនេះធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរបិទផ្លូវតវ៉ា ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ — ឯកសារថតចំលងត្រឹមត្រូវតាមច្បាប់ដើម

បាត្រហត្ថលេខា និងត្រា — លេខាធិការ

**ចាន់ សុក** — **ម៉េង គីមលី**

★★★

ភ្នំពេញ,ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨

## សេចក្តីសំរេច លេខ ១៥ កបធ/សសរ

## ក្រុមប្រឹក្សាធម្មនុញ្ញ

****

-យល់ឃើញថា ៖ ពាក្យបណ្តឹងជំទាស់លេខ ១៦២-៩៨ នពក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណបក្សហ្វ៊ុនស៊ិនប៉ិច ដែលទាក់ទងនឹងសេចក្តីសំរេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលេខ ០៨-១៦០៩/៩៨ គជប ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ដែលបដិសេធពាក្យបណ្តឹងលេខ ០៤៧/៩៨ នពក ចុះថ្ងៃទី០៤ ខែ សីហា ឆ្នាំ១៩៩៨ ដោយចោទពីភាពមិនប្រក្រតីរបស់ស្រុកឧត្តុង្គ និងបំពានសិទ្ធភ្នាក់ងារសង្កេតការណ៍ ដោយមូលហេតុក្នុងពេលរាប់សន្លឹកឆ្នោត អ្នកសង្កេតការណ៍របស់គណៈបក្សប្រឆាំង ត្រូវបានគណៈកម្មការមិនអោយមើលឃើញតារាងគូស និង ឯកភាពផងទេ មិនត្រឹមត្រូវទេ ។

-យល់ឃើញថា ៈ ភ្នាក់ងារសង្កេតការណ៍របស់គណបក្សនានា ក្នុងនោះក៏មានភ្នាក់ងារគណបក្សហ៊្វុនស៊ិនប៉ិច ផងដែរ បានចុះហត្ថលេខាលើឯកសារនានាដូចជា :-

- កំណត់ហេតុនៃការបោះឆ្នោត គជប ១១០១ គករ
- កំណត់ហេតុនៃការផ្ទៀងផ្ទាត់សន្លឹកឆ្នោត គជប ១១០២ គឃរ-សរប
- កំណត់ហេតុនៃការប្រមូលសរុបការរាប់សន្លឹកឆ្នោតនៅគណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោត គជប ១១០៣ គឃរ-សរប
- តារាងកត់ត្រាសន្លឹកឆ្នោត គជប ១១០៤ គឃរ-សរប

ជាភស្តុតាងនៃការទទួលស្គាល់ការបោះឆ្នោត និង ដំណើរការរាប់សន្លឹកឆ្នោតនៅគណៈកម្មការឃុំ-សង្កាត់រៀបចំការបោះឆ្នោតក្នុងភាពប្រក្រតីនិងគ្មានការប៉ះពាល់សិទ្ធិភ្នាក់ងារសង្កេតការណ៍គួរអោយកត់សំគាល់ឡើយ ។

-យល់ឃើញថា ៈ ពាក្យបណ្តឹងនេះគ្មានទឡ្ហីករណ៍គ្រប់គ្រាន់ ដើម្បីបើកសវនាការតាមមាត្រា១១៧ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គប្បីក្រុមប្រឹក្សាធម្មនុញ្ញសំរេចបដិសេធមិនទទួលយកពាក្យបណ្តឹងតវ៉ានេះ ។

-យល់ឃើញថា ៈ សេចក្តីសំរេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០៨-១៦០៨/៩៨ គជប ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ ១៩៩៨ មានលក្ខណៈត្រឹមត្រូវហើយ ។

**សំរេច**

១-បដិសេធពាក្យបណ្តឹងជំទាស់ លេខ ១៦២/៩៨ នគក ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ របស់គណបក្សហ៊្វុនស៊ិនប៉ិច ដែលទាក់ទងនិងសេចក្តីសំរេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ០៨-១៦០៨/៩៨ គជប ចុះថ្ងៃទី១១ ខែ សីហា ឆ្នាំ ១៩៩៨ ក្នុងការបដិសេធពាក្យបណ្តឹង លេខ ០៨៧-៩៨ នគក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៨ ដែលប្តឹងពីភាពមិនប្រក្រតី ចោលជាអាសាបង់ ។

២-តម្កល់សេចក្តីសំរេច របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត លេខ ០៨-១៦០៨/៩៨ គជប ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៨ ទុកជាបានការពេញទាំងមូល ។

៣-សេចក្តីសំរេចនេះធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ១៩៩៨ នាសម័យប្រជុំពេញអង្គ នៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសំរេចស្ថាពរបិទផ្លូវតវ៉ា ។

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ
ហត្ថលេខា និងត្រា
ចាន់ សុក

ដកស្រង់ត្រឹមត្រូវតាមច្បាប់ដើម
លេខាធិការ
ម៉េង គីមលី

★★★